# ក្រសួងពាណិជ្ជកម្ម

## នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

### គម្រោងកម្មវិធីគាំទ្រការអភិវឌ្ឍន៍ពាណិជ្ជកម្ម (TDSP)

**បទបង្ហាញស្តីពី: របកគំហើញ និង កិច្ចការទូទៅ នៃផ្នែកហិរញ្ញវត្ថុ**

**ភ្នំពេញ, ថ្ងៃទី៣០ ខែមករា ឆ្នាំ២០១២**

# ចំនុចសំខាន់ៗ នៃបទបង្ហាញ

១)- ការរៀបចំផែនការវគ្គបណ្តុះបណ្តាលសម្រាប់គម្រោងទាំងប្រាំ ដែលបានអនុម័តក្រោយគេក្នុងឆ្នាំ២០១១

២)- គម្រោងជាអាទិភាពចំនួនប្រាំ ដែលត្រូវលើកស្នើមកនាយកគ្រប់គ្រងគម្រោងសម្រាប់ឆ្នាំ២០១២

៣)- របាយការណ៍របកគំហើញផ្សេងៗ ដែលទាក់ទងនឹងការស្នើសុំបុរេប្រទាន និងការទូទាត់ជម្រះបញ្ជី

# គម្រោងដែលត្រូវរៀបចំផែនការវគ្គបណ្តុះបណ្តាលប្រចាំឆ្នាំ ២០១២

**១). MoC ICT Master Plan**

- សិក្ខាសាលា និងវគ្គបណ្តុះបណ្តាល សរុបចំនួន៨ **សរុបទឹកប្រាក់ចំនួន ១២៦,០០០ ដុល្លារអាមេរិក**

**២). GDCE Capacity Enhancement Programme**

- សិក្ខាសាលា វគ្គបណ្តុះបណ្តាល និង ដំណើរទស្សនៈកិច្ចសិក្សានៅក្រៅប្រទេសសរុបចំនួន១០ **សរុបទឹកប្រាក់ចំនួន២០៣,៧៣០ ដុល្លារអាមេរិក**

**៣). Implementing Agencies Capacity Enhancement Program (IACEP)**

- សិក្ខាសាលា និងវគ្គបណ្តុះបណ្តាល សរុបចំនួន៤ **សរុបទឹកប្រាក់ចំនួន ៣៧,៥០០ ដុល្លារអាមេរិក**

៤). **The development of national standards for rice and strengthening the capacity of conformity assessment body-Phase I (MIME)**

- សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលសរុបចំនួន២ និងប្រមូលទិន្នន័យសរុបចំនួន២ **សរុបទឹកប្រាក់ចំនួន៤៩,0៥៨.៥0 ដុល្លារអាមេរិក**

៥). **Better Quality and Safety of Fish and Fishery Products for Improving Fish Trade Development in Cambodia**

- សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលសរុបចំនួន១៨ **សរុបទឹកប្រាក់ចំនួន ៧៧,៥៥៩.00 ដុល្លារអាមេរិក**

# សំណើគម្រោងជាអាទិភាពប្រចាំឆ្នាំ២០១២

| ឈ្មោះគម្រោង | ថវិកាវិភាជន៍ |
| --- | --- |
| ១). Automating IP Administration System | • USD296,000.00 |
| ២). Capacity Building of Internal Audit Dep’t | • USD356,000.00 |
| ៣). SEZ Automation | • USD31,400.00 |
| ៤). Support to GPSF | • USD300,000.00 |
| ៥). Electronic Platform to Support Exporting Agricultural Products | • USD300,000.00 |

# របាយការណ៍របកគំហើញរបស់ផ្នែកហិរញ្ញវត្ថុ

- ភ្នាក់ងារអនុវត្តមួយចំនួន មានការជម្រុះបញ្ជីសាច់ប្រាក់បុរេប្រទានសម្រាប់រៀបចំសិក្ខាសាលា វគ្គបណ្តុះបណ្តាល និងដំណើរទស្សនៈកិច្ចសិក្សាក្នុង និងក្រៅប្រទេស មានការយឺតយ៉ាវលើសចំនួន១០ថ្ងៃ ក្រោយសកម្មភាពបានបញ្ចប់ ។
- ការដាក់សំណើរសុំសាច់ប្រាក់បុរេប្រទានសម្រាប់អនុវត្តសកម្មភាពនានា មកផ្នែកហិរញ្ញវត្ថុគម្រោង មានពេលតិចជាង៥ថ្ងៃ ឬក្នុងរយៈពេលសកម្មភាពកំពុងអនុវត្ត ។
- ចំណាយទិញសម្ភារៈការិយាល័យ និងការថតចម្លងឯកសារសម្រាប់អ្នកចូលរួម ត្រូវបានទិញជាកញ្ចប់ មិនបានលំអិតតម្លៃ និងឯកត្តានៃទំនិញនីមួយៗ ឬក៏ទំព័រ ។
- វិក្កយបត្រទិញទំនិញមួយចំនួន មិនបានបរិយាយមុខទំនិញដែលបានទិញ កាលបរិច្ឆេទ ហត្ថលេខា និងឈ្មោះអ្នកទិញ និងអ្នកលក់ និងបានលក់ទៅឲ្យអ្នកណា ។

- ភ្នាក់ងារអនុវត្តមួយចំនួន បានជួលឧបករណ៍ប្រើប្រាស់សម្រាប់ជំនួយក្នុងអង្គសិក្ខាសាលា និងវគ្គបណ្តុះបណ្តាល នៅពេលដែលឧបករណ៍ដូចគ្នានោះត្រូវបានផ្តល់ឲ្យដោយគម្រោងរួចហើយ ។
- លិខិតស្នើសុំសម្រង់តម្លៃ និងលិខិតបញ្ជាទិញទំនិញ និងសេវាកម្មនានា មិនត្រូវបានប្រើប្រាស់ជាទូទៅសម្រាប់ធានារាល់ការទូទាត់ចំណាយ ។
- វិក្កយបត្រសម្រាប់ការទូទាត់ចំណាយទិញទំនិញ និងសេវាកម្មរបស់អ្នកផ្គត់ផ្គង់ជាច្បាប់ចម្លងដែលទុកសម្រាប់ប្រើប្រាស់កិច្ចការផ្ទៃក្នុងរបស់គេ ហើយក៏មានការប្រើប្រាស់របាយការណ៍ពិនិត្យដើម្បីជួសជុល ជំនួសវិក្កយបត្រផងដែរ ។
- លិខិតបញ្ជាបេសកកម្ម និងទិដ្ឋាការធ្វើដំណើររបស់មន្ត្រីថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិដែលបានចូលរួមសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលមិនបានបំពេញត្រឹមត្រូវ ។

- សម្រាប់អង្គសិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗរបស់គម្រោង ផ្នែកហិរញ្ញវត្ថុ បានរកឃើញថា ភ្នាក់ងារអនុវត្តបានអនុញ្ញាតឲ្យប្រពន្ធផ្សព្វផ្សាយចូលរួម ដើម្បីធ្វើការផ្សព្វផ្សាយព័ត៌មាន សកម្មភាពរបស់គម្រោង ។

- មានការប្រើប្រាស់កញ្ចប់បេឡាសាច់ប្រាក់ដើម្បីទិញឧបករណ៍ទប់ចរន្តអគ្គីសនីចំនួនប្រាំគ្រឿង និងឧបករណ៍ភ្ជាប់អ៊ិនធឺណែត ដោយមិនមានការជូនដំណឹងនិងការស្នើសុំជាមុនពីនាយកគម្រោង នៅពេលដែលឧបករណ៍ដូចគ្នានោះត្រូវបានផ្តល់ឲ្យ ដោយគម្រោងរួចហើយ ។

- វិក្កយបត្រទូទាត់របស់អ្នកផ្គត់ផ្គង់ ត្រូវបានភ្នាក់ងារអនុវត្តមួយចំនួនប្រើប្រាស់លេខរៀងវិក្កយបត្រទាំងអស់នោះតាមលំដាប់លេខរៀង ទោះបីជាកាលបរិច្ឆេទទិញទំនិញមានការខុសគ្នាក៏ដោយ ។

- មានការចំណាយទិញសម្ភារៈនិងសេវាកម្ម ដែលមានតម្លៃច្រើនជាង **USD200.00** (ពីររយដុល្លារអាមេរិក) ចេញពីកញ្ចប់បេឡាសាច់ប្រាក់របស់ភ្នាក់ងារអនុវត្ត ។

- ការចំណាយទិញទឹក តែ និងកាហ្វេ សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ ត្រូវបានឃើញកើតមានចំពោះភ្នាក់ងារអនុវត្តមួយចំនួន ។

- មន្ត្រីបង្គោល និងភ្នាក់ងារដែលមានភារៈកិច្ចធ្វើការទំនាក់ទំនងជាមួយផ្នែកហិរញ្ញវត្ថុ មិនមែនជាមន្ត្រីតែមួយរូប ។

# សំណួរ និង ចម្លើយ

# សូមអរគុណ

Thank you